

# ផ្កាជូនអ្នកជិតខាងខ្ញុំ



ដោយ ភីធើរ អ៊ី អាយុ ១០ ឆ្នាំ រស់នៅរដ្ឋយូថាហ៍ ស.រ.អា.

ប៉ុន្មានឆ្នាំមុន ស្វាមីរបស់អ្នកជិតខាងខ្ញុំបានស្លាប់ ។ គាត់ពិតជាសោកសៅខ្លាំងណាស់ ។

ខ្ញុំដឹងថាវាមានអារម្មណ៍បែបណា នៅពេលបាត់បង់មនុស្សដែលយើងស្រឡាញ់ ។ ពេលខ្ញុំអាយុបីឆ្នាំ ម្ដាយខ្ញុំបានស្លាប់ ។ បន្ទាប់ពីគាត់ស្លាប់ ក្មេងៗនៅតំបន់ជិតខាងរបស់ខ្ញុំបានសរសេរសំបុត្រឲ្យបងប្រុសខ្ញុំ និងខ្ញុំ ហើយតុបតែងទីធ្លារបស់យើងដោយប្រើរបស់លេង ។ ខ្ញុំចង់ធ្វើអ្វីមួយដ៏ល្អសម្រាប់អ្នកជិតខាងរបស់ខ្ញុំដែរ ។

ខ្ញុំបានអធិស្ឋានដើម្បីដឹងពីអ្វីដែលខ្ញុំអាចធ្វើដើម្បីជួយគាត់ ។ គំនិតមួយបានផុសឡើងក្នុងចិត្តរបស់ខ្ញុំ គឺជូនផ្កាដល់គាត់នៅថ្ងៃនៃក្ដីស្រលាញ់ ។ ទោះជាយ៉ាងណា ខ្ញុំត្រូវរកប្រាក់ដើម្បីទិញផ្កា ។ ខ្ញុំបានដាក់គោលដៅមួយនៅក្នុង *កូនសៀវភៅណែនាំកុមារ* ត្រូវរកប្រាក់ ។

ខ្ញុំរកប្រាក់ដោយធ្វើការងារផ្សេងៗឲ្យអ្នកដទៃ ។ លោកយាយខ្ញុំបានបង់ប្រាក់ឲ្យខ្ញុំដើម្បីសម្អាតសួនច្បារ និងស្លឹកឈើនៅក្នុងទីធ្លារបស់គាត់ ។ នៅផ្ទះ ខ្ញុំរកបានប្រាក់ដោយសម្អាតស្មៅខាងក្រោយផ្ទះដាក់អីវ៉ាន់របស់យើង ។ វាត្រូវការការខិតខំជាច្រើនខែដើម្បីរកប្រាក់គ្រប់គ្រាន់ ។ ទីបំផុតខ្ញុំមានលុយគ្រប់គ្រាន់ដើម្បីទៅហាងមួយ ហើយទិញផ្កានោះ ។ ទិវានៃក្ដីស្រលាញ់បានមកដល់ ហើយខ្ញុំបានជូនផ្កាដល់អ្នកជិតខាង ជាមួយនឹងសំបុត្រមួយ ។ គាត់សប្បាយចិត្តខ្លាំងណាស់ ។ ខ្ញុំក៏មានអារម្មណ៍កក់ក្ដៅ និងរីករាយផងដែរ ។ ខ្ញុំបានអរព្រះគុណព្រះវរបិតាសួគ៌ដែលបានជួយខ្ញុំឲ្យធ្វើអ្វីដែលទ្រង់សព្វព្រះទ័យឲ្យខ្ញុំធ្វើ ។ ●